**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ១៥៤
ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៨
**សាលដីកា**
លេខៈ៣១
ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ........... ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............ ជាចៅក្រម
៣-លោក ............. ជាចៅក្រមរបាយការណ៍
៤-លោក ............... ជាចៅក្រម
៥-លោក ................ ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក .................

**តំណាងមហាអយ្យការ**
-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧៣ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះហាឈ អាយុ៤៩ឆ្នាំ មុខរបរធ្វើស្រែ ទីលនៅភូម៣ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនៈគីរី ។ ឪពុកឈ្មោះប្រាក់ ពីក(រ) ម្តាយឈ្មោះសៀក(ស) ប្រពន្ធឈ្មោះទំ អ៊ាន មានកូន០៦នាក់ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះធអ កេទស្រី អាយុ៦៥ឆ្នាំ មុខរបរធ្វើស្រែ ទីនៅភូមិ១ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនៈគីរី ។ ឪពុកឈ្មោះធន (ស) ម្តាយឈ្មោះគឹម ទូច(ស) ប្តីឈ្មោះ សេង មានកូន០២នាក់ ។

**កម្មវត្ថុបណ្តឹង** ប្តឹងទាមទារដី ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨ របស់ឈ្មោះហាឈ ប្តឹងមិនសុខចិត្តនិងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៥៤ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៥ របស់ឈ្មោះឆអ ប្តឹងពីឈ្មោះហាឈ រំលោភលើដីធ្លីកម្មសិទ្ធិរបស់ខ្លួនដោយសំអាងហេតុថា ឈ្មោះហាឈ ក្រោយពីមានការព្រមព្រៀងជាមួយឈ្មោះសុង ហើយសង់ផ្ទះលើដីរបស់ខ្លួន ។ ខ្លួនសំណូមពរទាមទាររបស់ខ្លួនព្រោះដីនេះខ្លួនមានប័ណ្ណកម្មសិទ្ធិរួចហើយ ។

បានឃើញសាលក្រមលេខ០៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦ របស់តុលាការខេត្តរតនៈគីរី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលស្គាល់ពាក្យបណ្តឹងរបស់អ្នកស្រីឆអ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-លោកឆន់ ប៊ុនសុង ត្រូវចេញប្រាក់ចំនួន១០០.០០០(ដប់ម៉ឺនរៀល) ឱ្យទៅលោក ហាឈ វិញ ។

៣-លោកហាឈ ត្រូវរុះផ្ទះចេញពីដីដែលមានទំនាស់ រួចប្រគល់ឱ្យទៅអ្នកស្រីឆអ កាន់កាប់ជាកម្មសិទ្ធិស្របច្បាប់តទៅ ។

Б ៤- សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូក្តី

៥-បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍រយៈពេល២ខែគិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៧៣ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៧ ប្តឹងមិនសុខចិត្តលើសេចសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១-០៧-១៩៩៦ របស់ដើមបណ្តឹងឧទ្ធរណ៍ ឈ្មោះហាឈ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ខុសនិងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ០៣ ចុះថ្ងៃទី២៨-០៥-១៩៩៦ របស់តុលាការ ខេត្តរតនៈគីរី ទុកជាបានការ ។

៣-សម្រេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល និងលើអាជ្ញាធរតុលាការ៥.០០០រៀល ។

- កាលបើសាលដីកានេះចូលជាស្ថាពរហើយ បង្គាប់ឱ្យឈ្មោះហាឈ បង់ពន្ធសមាមាត្រ១% លើប្រាក់១០០.០០០រៀល ។ ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋ៨០% និងដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៤- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។

សម្រេចបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី១២-០៣-៩៨ របស់លោកហាឈ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាការពាររបស់ឈ្មោះហាឈ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៨ ។

បានឃើញសារណាតបរបស់ឈ្មោះធអ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៨ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយករណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា សាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបានតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់សារណារបស់ឈ្មោះហាឈ នៅពេលជំនុំជំរះ ។

បានស្តាប់សារណាតបរបស់ឈ្មោះធអ នៅពេលជំនុំជំរះ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថាបណ្តឹងសាទុក្ខលេខ៥៧ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨ របស់លោកហាឈ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តី ការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាការដែលលោកហាឈ អះអាងថា ប័ណ្ណសម្គាល់សិទ្ធិលេខ៤១_១៧៥ ចុះថ្ងៃទី១៤-០១-៩៤ របស់លោកធន់ ប៊ុនហៀង ជាប័ណ្ណកម្មសិទ្ធិក្លែងបន្លំនោះ ពុំមានភស្តុតាងណាបញ្ជាក់គួរឱ្យជឿបានឡើយហើយការសំអាងទៅលើគណៈកម្មការវាស់វែងដែលថាក្នុងការវាស់ដីឱ្យលោកធន់ ប៊ុនហៀង គឺធ្វើចាប់ពីបារ៉ែតទៅក្រោយនោះ ក៏ជាការពុំត្រឹមត្រូវដែរ ពីព្រោះថាពាក្យសុំចុះថ្ងៃទី១៥-០៧-៩០ របស់លោកធន់ ប៊ុនហៀង បានកំណត់ព្រំខាងលិច ទល់នឹងថ្នល់ដែរ ដូច្នេះដីដែលលោកហាឈ សង់ផ្ទះនោះ ជាដីដែលស្ថិតក្នុងប័ណ្ណកម្មសិទ្ធិលេខ៤១-១៧៥ ប្រាកដមែន ។

-យល់ឃើញថាការដែលតុលាការខេត្តរតនៈគីរីក៏ដូចសាលាឧទ្ធរណ៍ដែរ ដែលសំរេចឱ្យលោកធន់ ប៊ុន សុង សងប្រាក់ចំនួន១០០.០០០រៀល ទៅលោកហាឈ នោះជាការខុសឆ្គង ពីព្រោះថា សាលាជំរះទាំងពីរនេះពុំបានចាត់របៀបបញ្ចូលលោកធន់ ប៊ុនសុង មកក្នុងរឿងក្តីនេះផង និងពុំមានពាក្យសុំពីគូក្តីណាមួយផង ។

- យល់ឃើញថា គូភាគីនៃរឿងក្តីនេះបានធ្វើសារណការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការរួច ហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២.០៣.៩៨ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ លើកលែងចំណុចទី២ នៃសាលក្រមលេខ០៣ ចុះថ្ងៃទី ២៨-០៥-៩៨ របស់តុលាការខេត្តរតនៈគីរី ដែលត្រូវទុកជាមោឃៈ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីកំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី១២-០៣-៩៨ របស់លោកហាឈ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២.០៣.៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងចំណុចទី២ នៃសាលក្រមរដ្ឋប្បវេណីលេខ០៣ ចុះថ្ងៃទី២៨.០៥.៩៦ របស់តុលាការខេត្តរតនៈគីរី ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៥៤ ចុះថ្ងៃទី២២.០៥.៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញត្រង់ចំណុចទី២ នៃសាលក្រមរដ្ឋប្បវេណីលេខ០៣ ចុះថ្ងៃទី ២៨.០៥.៩៦ របស់តុលាការខេត្តរតនៈគីរី ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកហាឈ បានបង់រួចហើយគឺ ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

-បង្គាប់ឱ្យលោកហាឈ បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីទំនាស់ ។

៥- សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩ ។